# រឿងនាងសុភទ្រា

( ចាក វិ. ខុ. )

( គុណនៃការធ្វើសង្ឃគតាទក្ខិណាទាន )

កាល ព្រះសម្ពុទ្ធបរមគ្រូ គង់នៅក្នុងវត្តជេតពន នាក្រុងសាវត្ថី ។ កាលនោះមាន កុដុម្ពិក៍ម្នាក់ ជាញោមឧបដ្ឋាកព្រះរេវតត្ថេរ នៅក្នុងនាឡន្តគ្រាម ។

កុដុម្ពិក៍នោះ មានកូនស្រីពីរនាក់ ឈ្មោះភទ្រា ១. សុភទ្រា ១. នាងភទ្រា មានស្វាមី ទៅនៅក្នុងត្រកូលមាតាបិតាក្មេក ប៉ុន្តែនាងជាស្រ្តីអាឥតកូន នាងបាននិយាយនឹងស្វាមីថា ខ្ញុំមានប្អូនស្រីមួយឈ្មោះសុភទ្រា ខ្ញុំនឹងនាំមកជាភរិយារបស់អ្នក ដើម្បីឱ្យបានបុត្រ ។ បុរសជាស្វាមីព្រមទទួលតាមពាក្យរបស់នាង ។

ឯនាងភទ្រា ជាស្រ្តីមានសទ្ធាមុតមាំក្នុងព្រះពុទ្ធសាសនា បានរំឭកដាស់តឿន នាងសុភទ្រាជាប្អូន ឱ្យខំធ្វើទានរក្សាសីល បំពេញការកុសលគ្រប់បែបយ៉ាង ។ នាងសុភទ្រា ក៏ខំប្រតិបត្តិតាមឱវាទ របស់បង ។

ថ្ងៃមួយ នាងបាននិមន្តព្រះរេវតត្ថេរ ព្រមទាំងភិក្ខុដទៃទៀតជាគំរប់ ៨ អង្គ មកថ្វាយសង្ឃទាន ក្នុងគេហស្ថានរបស់នាង ។ ព្រះរេវតត្ថេរ លោកមានព្រះទ័យករុណា ចង់ឱ្យនាងសុភទ្រាបានបុណ្យច្រើន លោកក៏នាំភិក្ខុសង្ឃទាំង ៧ អង្គ ឡើងគង់លើ អាសនៈហើយប្រាប់ថា នាងចូរថ្វាយទានដល់សង្ឃចុះ ។ នាងសុភទ្រា ក៏លើកភោជនហារ ទៅប្រគេនព្រះសង្ឃទាំង ៨ អង្គ បានតាំងចិត្តចំពោះសង្ឃតែម្យ៉ាង លុះឆាន់ហើយព្រះរេវតត្ថេរ បានធ្វើភត្តានុមោទនារួច ក៏និមន្តទៅ អារាមវិញទៅ ។

ចំណែក ខាងនាងសុភទ្រា ដល់អស់អាយុ បានទៅកើតក្នុងស្ថាន និម្មានរតី ។ ឯនាងភទ្រាជាបង ដែលជាអ្នកពេញចិត្តក្នុងការធ្វើទាន ដល់អស់អាយុ បានទៅកើតជាបាទបរិច្ចារិកា របស់ព្រះឥន្ទ្រ នាស្ថានត្រៃត្រឹង្ស ។

ក្នុងពេលនោះនាងសុភទ្រាទេវធីតា បានរំពឹងមើលបុព្វកម្មរបស់ខ្លួន ឃើញថា ដែលបានមកកើតក្នុង ស្ថាននិម្មានរតីនេះ ដោយសាឱវាទរបស់នាងភទ្រាជាបង ។ ទើបនាងនឹករកនាងភទ្រា ក៏ឃើញក្នុងស្ថានត្រៃត្រឹង្ស មានយសស័ក្តិទាបជាងនាង នាង មានចិត្តអាណិតបងខ្លាំងណាស់ ទើបហោះចុះទៅស្ថានត្រៃត្រឹង្ស ចូល

ទៅក្នុងប្រាសាទនាងភទ្ទាទេវធីតា ។

នាងភទ្ទាទេវធីតានោះ មិនស្គាល់ជាប្អូនរបស់ខ្លួនឡើយ ទើបសួរថា ម្នាលនាងមានតេជៈច្រើន ថ្កើងរុងរឿងដោយពន្លឺរស្មី គ្រប់ដណ្តប់នូវពួកទេវតាក្នុងជាន់ត្រៃតឹង្ស ។ នាងមកពីស្ថានណា ? បានធ្វើបុណ្យដូចម្តេចពីជាតិមុន ? ។ នាងសុភទ្ទាទេវធីតាប្រាប់ថា បពិត្រអ្នកបង ខ្ញុំមកពីស្ថាននិម្មានរតី កាលពីជាតិមុន ខ្ញុំត្រូវជាប្អូនបង្កើតរបស់អ្នកបង ដែលខ្ញុំមានតេជៈរុងរឿងយ៉ាងនេះ ដោយសាឱវាទរបស់អ្នកបង ។

នាងភទ្ទាសួរទៀតថា ម្នាលនាងទេពធីតា នាងបានធ្វើបុណ្យអ្វី បានមានបុណ្យស័ក្តធំជាងយើង ? យើង កាលនៅស្ថានមនុស្ស បានធ្វើបុណ្យច្រើនណាស់ ហេតុអ្វីក៏មានស័ក្តិតូចដូច្នេះ ? ។ នាងសុភទ្ទាប្រាប់ថា អ្នកបងធ្វើទានច្រើនមែន ប៉ុន្តែបានធ្វើតែបុគ្គលិកទាន ឯខ្លួនខ្ញុំបានធ្វើទាន តែចំពោះព្រះសង្ឃ ៨ អង្គ ទាននោះឈ្មោះថាសង្ឃទាន ព្រោះខ្ញុំតាំងចិត្តចំពោះសង្ឃតែម្យ៉ាង បានជាខ្ញុំមានស័ក្តិធំជាងអ្នកបង ។ និយាយដូច្នេះហើយ ក៏លានាងភទ្ទាត្រឡប់ទៅស្ថានរបស់ខ្លួនវិញ ។

ថ្ងៃមួយ ព្រះមោគ្គល្លាននិមន្តទៅស្ថានត្រៃត្រឹង្ស បានជ្រាបប្រវត្តិរបស់នាងទាំងពីរអំពីសំណាក់ព្រះឥន្ទ្រហើយ ក៏ចុះមកស្ថានមនុស្សវិញ នាំដំណើរនោះ ទៅក្រាបទូលដល់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគ ទ្រង់ប្រារព្ធនូវរឿងនោះ ឱ្យជាហេតុហើយ ទើបសំដែងនូវ អានិសង្សនៃសង្ឃគតាទក្ខិណាទាន ជាតិយេ្យាភាពតទៅ ។

សូមអស់លោកអ្នកអនុមោទនា !

ចប់